ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
លេខ: ✓

# សេចក្តីប្រកាសព័ត៌មាន

អគ្គិសនីកម្ពុជា មានកិត្តិយសសូមជម្រាបជូនសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាធារណជន មេត្តាជ្រាបថា នៅព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៦ អគ្គិសនីកម្ពុជា បានធ្វើម្ចាស់ផ្ទះនៅរាជធានីភ្នំពេញ ដើម្បីរៀបចំ **"ពិធីចុះហត្ថលេខាលើក្របខ័ណ្ឌសិក្សារួមស្តីពីការសិក្សាសមិទ្ធិលទ្ធភាពតភ្ជាប់ប្រព័ន្ធខ្សែបណ្តាញបញ្ជូនអគ្គិសនី កម្ពុជា-ឡាវ"** រវាងអគ្គិសនីកម្ពុជា (EDC)-អគ្គិសនីឡាវ (EDL)-ASEAN Center for Energy (ACE) និងកិច្ចប្រជុំពាក់ព័ន្ធ ដែលមានវត្តមានចូលរួមជាកិត្តិយសរបស់ **ឯកឧត្តម វិចទ័រ ហ្យូនា** ឧត្តមមន្ត្រីថាមពលអាស៊ាន (Senior Official on Energy-SOE) និងជាអនុរដ្ឋលេខាធិការ នៃក្រសួងរ៉ែ និងថាមពល និងតំណាងអាជ្ញាធរអគ្គិសនីកម្ពុជា តំណាងក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម ប្រទេសឡាវ និងធនាគារពិភពលោក (World Bank)។ គម្រោងសិក្សារួមនេះ ទទួលបានជំនួយហិរញ្ញប្បទានពី ធនាគារពិភពលោក (World Bank) ដែលមាន ACE ជាលេខាធិការដ្ឋានសម្របសម្រួល។ ការសិក្សានេះនឹងក្លាយជាមូលដ្ឋានដើម្បីគាំទ្រ និងអភិវឌ្ឍន៍ការធ្វើពាណិជ្ជកម្មថាមពលក្នុងដំណាក់កាលដំបូង រវាងប្រទេសទាំងពីរ និងឈានដល់ការធ្វើពាណិជ្ជកម្មទូលាយក្នុងវិស័យថាមពលក្នុងតំបន់ ដែលក្នុងនោះការធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រង និងដំណើរការប្រព័ន្ធខ្សែបណ្តាញបញ្ជូនអគ្គិសនី ជាផ្នែកមួយដ៏សំខាន់សម្រាប់ការសិក្សានេះ។

លើសពីនេះ លទ្ធផលនៃការសិក្សា នឹងជំរុញដល់ការអភិវឌ្ឍគម្រោងថាមពលបៃតងជាគោល ដែលជាសក្តានុពលក្នុងប្រទេសទាំងពីរ ដើម្បីពង្រឹងសន្តិសុខថាមពល កាត់បន្ថយលើការនាំប្រេងឥន្ធនៈមកផលិតអគ្គិសនី និងជំរុញកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក។

អាស្រ័យហេតុនេះ សូម សម្តេចទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ច័ន្ទ ០៩ កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០២៦

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា: #២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១